**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ ៣៣៥០ អពដ

ថ្ងៃសុក្រ ០៨ កើត ខែស្រាពណ៍ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ សីហា ឆ្នាំ ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញសហគ្រាសមកទូទាត់បំណុលពន្ធ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនលោក-លោកស្រី នាយកសហគ្រាសដែលជំពាក់បំណុលពន្ធទាំងអស់ថា ការបង់ពន្ធអាករ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូបដើម្បីចូលរួមចំណែកក្នុងការកៀរគរថវិការដ្ឋសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិលើគ្រប់វិស័យ។ កន្លងមក អគ្គនាយកដ្ឋានពន្ធដារបានសង្កេតឃើញថា សហគ្រាសមួយចំនួនបានចូលខ្លួនមកធ្វើការទូទាត់បំណុលពន្ធតាមការអញ្ជើញរបស់អគ្គនាយកដ្ឋានពន្ធដារ។ ទន្ទឹមនេះ នៅមានសហគ្រាសមួយចំនួនទៀតមិនបានចូលខ្លួនមកទូទាត់បំណុលពន្ធរបស់ខ្លួននៅឡើយទេ។

ហេតុនេះ អគ្គនាយកដ្ឋានពន្ធដារ សូមអញ្ជើញអស់លោក-លោកស្រីនាយកសហគ្រាសដែលជំពាក់បំណុលពន្ធទាំងអស់មកធ្វើការទូទាត់បំណុលពន្ធរបស់ខ្លួននៅអគ្គនាយកដ្ឋានពន្ធដារដែលមានទីតាំងនៅកែងមហាវិថីសហព័ន្ធរុស្ស៊ី និងមហាវិថីម៉ៅសេទុង សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក បន្ទប់លេខ**២០៨** ទូរស័ព្ទទំនាក់ទំនងលេខ **០២៣ ៨៨៤ ៨០០**។

ក្នុងករណីដែលលោក-លោកស្រីនាយកសហគ្រាសខកខានមិនបានមកទូទាត់បំណុលពន្ធនោះទេ អគ្គនាយកដ្ឋានពន្ធដារនឹងចាត់វិធានការចុះផ្សាយលើទំព័រសារព័ត៌មាន នូវឈ្មោះសហគ្រាស និងកម្មសិទ្ធិករក្នុងពេលឆាប់ៗខាងមុខនេះ ហើយនឹងបន្តចាត់វិធានការតឹងទារបំណុលពន្ធ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន ដូចខាងក្រោម÷

- សហការជាមួយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាដើម្បីបញ្ឈប់ការនាំចេញ-នាំចូល
- សហការជាមួយធនាគារជាតិដើម្បីឃាត់ទុកគណនីធនាគាររបស់អ្នកជាប់ពន្ធ
- សហការជាមួយស្ថាប័នតុលាការដើម្បីឃុំគ្រង និងរឹបអូសលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ
- សហការជាមួយអគ្គស្នងការនគរបាលជាតិដើម្បីនាំខ្លួនអ្នកជាប់ពន្ធឱ្យមកទូទាត់បំណុលពន្ធ
- ការឃាត់ទុកការផ្ទេរកម្មសិទ្ធិអចលនទ្រព្យនិងភាគហ៊ុនចំពោះសហគ្រាសដែលជំពាក់បំណុលពន្ធ
- ការទុកជាមោឃៈ នូវលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណផ្សេងៗជាដើម។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមជឿជាក់យ៉ាងមុតមាំលើស្មារតីទទួលខុសត្រូវខ្ពស់របស់លោក-លោកស្រីនាយកសហគ្រាសក្នុងការអញ្ជើញមកទូទាត់បំណុលពន្ធ តាមទីកន្លែងកំណត់ខាងលើកុំបីខានឡើយ។

Collection by VCAT Professional Consultant

**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh